ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៤០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និង នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ .-

ត្រូវបានបង្កើតនាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម ចំណុះនាយកដ្ឋានកណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

មាត្រា២ .-

នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារត្រួតពិនិត្យបែបបទសំណុំឯកសារពាក់ព័ន្ធការស្នើសុំច្បាប់អនុញ្ញាតធ្វើអាជីវកម្មផ្នែកសន្តិសុខឯកជន និងជ្រើសរើសកម្លាំងភ្នាក់ងារសន្តិសុខឯកជន ។/.

www.pheakdeylaw.com

- ផ្តល់ការហ្វឹកហ្វឺន បណ្តុះបណ្តាលជំនាញឯកទេស និងច្បាប់ដល់កងកម្លាំងភ្នាក់ងារសន្តិសុខឯកជន និងចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា ។
- គ្រប់គ្រងសកម្មភាពរបស់បណ្តាក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន សហគ្រាស គ្រឹះស្ថានសន្តិសុខឯកជន អនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍កំណត់ ។
- ត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍ សម្ភារបច្ចេកទេស មធ្យោបាយ ឬសត្វ សម្រាប់បម្រើសកម្មភាពការពារសន្តិសុខ ។
- ផ្តល់កិច្ចសហការជាមួយក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ការពារទីតាំងសំខាន់ៗ និងការដឹកជញ្ជូនប្រាក់ ទ្រព្យសម្បត្តិ វត្ថុមានតម្លៃស្របច្បាប់ ។
- លើកយោបល់ជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ដើម្បីសុំគោលការណ៍លុបចោល ឬផ្អាកសកម្មភាពជាបណ្តោះអាសន្ន ឬដកហូតលិខិតអនុញ្ញាតប្រកបអាជីវកម្ម ឬផ្តល់ឡើងវិញចំពោះក្រុមហ៊ុនផ្តល់សេវាសន្តិសុខឯកជន ដែលធ្វើសកម្មភាពផ្ទុយពីគោលការណ៍កំណត់ ។
- ជំរុញ ការលើកកម្ពស់វិស័យសន្តិសុខឯកជន ចូលរួមចំណែកការពារសន្តិសុខ និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈ ។
- ប្រមែប្រមូលព័ត៌មាន ធ្វើរបាយការណ៍អំពីសភាពការណ៍ និងហេតុការណ៍ផ្សេងៗតាមឋានានុក្រមជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ តាមការកំណត់ ។
- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

មាត្រា៣ .-

នាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម មានតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- ធ្វើជាសេនាធិការជូននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ លើការងារប្រយុទ្ធប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ។
- សហការជាមួយម្ចាស់កាស៊ីណូ ក្លឹបកម្សាន្ត ដើម្បីត្រួតពិនិត្យបច្ចេកទេសល្បែង និងមុខសញ្ញាហាមឃាត់ចូលលេងល្បែង ។
- ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបការលេងល្បែងស៊ីសងគ្រប់ប្រភេទ ។
- ស្រាវជ្រាវ ស៊ើបអង្កេត បង្ក្រាបការសម្អាតប្រាក់ បទល្មើសពាក់ព័ន្ធនិងបច្ចេកទេសល្បែងក្នុងកាស៊ីណូ ក្លឹបកម្សាន្ត ។
- ត្រួតពិនិត្យការប្រើប្រាស់ឧបករណ៍ សម្ភារបច្ចេកទេសល្បែងពាណិជ្ជកម្មគ្រប់ប្រភេទ ដើម្បីបម្រើឱ្យការងារជំនាញ ។
- ជំរុញ ការធ្វើអាជីវកម្មល្បែងពាណិជ្ជកម្មឱ្យអនុវត្តតាមគោលការណ៍ច្បាប់ ។
- គ្រប់គ្រងរមណីយដ្ឋាន ក្លឹមកម្សាន្ត និងល្បែងភ្នាល់គ្រប់ប្រភេទ តាមគោលការណ៍កំណត់ ។
- សិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលជំនាញបច្ចេកទេសល្បែងពាណិជ្ជកម្ម ។
- ធ្វើរបាយការណ៍ជូននាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ តាមការកំណត់។

www.pheakdeylaw.com

- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋាន តាមការកំណត់ ។
- បំពេញភារកិច្ចផ្សេងៗទៀត ដែលនាយកដ្ឋានកណ្តាលសន្តិសុខ អគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

មាត្រា៤ ._

នាយកដ្ឋាននីមួយៗដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ ។

មាត្រា៥ ._

នាយកដ្ឋានគ្រប់គ្រងសន្តិសុខឯកជន មានការិយាល័យចំណុះមួយចំនួន និងនាយកដ្ឋានប្រឆាំងបទល្មើសល្បែងពាណិជ្ជកម្ម មានការិយាល័យចំណុះមួយចំនួន ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋាននីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

មាត្រា៦ ._

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា៧ ._

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៦

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
សូមឡាយព្រះហស្ថលេខា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្តេចក្រឡាហោម ស ខេង

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com